United Nations Human Rights

OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

# មតិយោបល់លើបទបញ្ញត្តិមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ ទាក់ទងនឹងស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ

ខែឧសភា ឆ្នាំ២០១៤

មតិយោបល់ខាងក្រោម ត្រូវបានរៀបចំដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីជួយដល់ដំណើរការនៃការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ។ មតិយោបល់ទាំងនេះ ផ្អែកជាចំបងលើកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជា។ ការអនុម័តច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ ផ្តល់ឱកាសដ៏សំខាន់មួយដល់ប្រទេសកម្ពុជា ក្នុងការពង្រឹងនូវការអនុវត្តតាមកាតព្វកិច្ចអន្តរជាតិទាំងនេះ។

សេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការកែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាច្បាប់មូលដ្ឋាន៣អំពីវិស័យតុលាការ។នីតិរដ្ឋមិនអាចមាននោះទេ ប្រសិនបើគ្មានមូលដ្ឋានច្បាប់ដ៏រឹងមាំសម្រាប់ប្រព័ន្ធយុត្តិធម៌។ ច្បាប់មូលដ្ឋានទាំង៣នេះ មានសារៈសំខាន់ណាស់ ក្នុងការបង្កើតប្រព័ន្ធយុត្តិធម៌មួយឲ្យដំណើរការ មានប្រសិទ្ធភាព និងត្រឹមត្រូវ ដែលជាលទ្ធផលធានានូវការការពារសិទ្ធិមនុស្សតាមផ្លូវច្បាប់ កាន់តែប្រសើរ នៅក្នុងប្រទេសកម្ពុជា។ ការអនុម័តច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការនេះ ត្រូវបានកំណត់រួចហើយនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ជាការពិតណាស់ មាត្រា ១៣៥ នៃរដ្ឋធម្មនុញ្ញចែងថា "លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងការរៀបចំអង្គការតុលាការ នឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា"។

កាលពីខែកុម្ភៈ ឆ្នាំ២០១៤ ការិយាល័យបានដាក់ជូនមតិយោបល់ម្តងរួចមកហើយ ដល់ក្រសួងយុត្តិធម៌ ហើយការិយាល័យសូមធ្វើការកត់សំគាល់ដោយក្តីរីករាយថា មតិយោបល់មួយចំនួនដែលបានផ្តល់ជូនកាលនោះ ឃើញមានឆ្លុះបញ្ចាំងនៅក្នុងសំណៅចុងក្រោយនៃសេចក្តីព្រាងនេះ។ ដូចលើកមុនដែរ មតិយោបល់លើកនេះ ផ្តោតលើបញ្ញត្តិនានាដែលអាចជាបញ្ហា ព្រមទាំងលើផ្នែកមួយចំនួនដែលការិយាល័យយើងខ្ញុំជឿថាគួរត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងនេះ។ ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ បង្ហាញពីជំហានទៅមុខយ៉ាងសំខាន់ និងដែលរង់ចាំជាយូរមកហើយ

នៅក្នុងការពង្រឹងប្រព័ន្ធតុលាការនៅកម្ពុជា។ នៅក្នុងន័យនេះ អ្នករាយការណ៍ពិសេសអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានផ្តល់មតិយោបល់កាលពីលើកមុន នៅក្នុងរបាយការណ៍របស់លោកស្តីពីស្ថាប័នតុលាការថា "អវត្តមាននៃច្បាប់ស្តីពីការចាត់តាំង និងការប្រព្រឹត្តិទៅនៃអង្គការតុលាការ ហាក់បីដូចជាមានផលប៉ះពាល់នាំឲ្យខូចខាតដល់ប្រសិទ្ធភាព និងឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ ក្នុងការផ្តល់យុត្តិធម៌ឱ្យបានលឿន និងមិនលំអៀង។ ច្បាប់នេះមានភាពចាំបាច់ ដើម្បីសម្រេចបាននូវកម្រិតនៃការឯកភាព សុគតភាព និងភាពច្បាស់លាស់ក្នុងប្រព័ន្ធយុត្តិធម៌។"[1]

*ដើម្បីជាប្រយោជន៍ដល់ការបង្កើតនូវការអនុវត្តល្អៗ ការិយាល័យឧត្តមស្នងការសូមផ្តល់អនុសាសន៍ថា គួរតែរៀបចំឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈមួយ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ។ នៅក្នុងន័យនេះ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនជាស្រេច ដើម្បីផ្តល់ជាជំនួយក្នុងការរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈបែបនេះ។ លើសពីនេះ ការិយាល័យឧត្តមស្នងការ ត្រៀមខ្លួនជាស្រេច ដើម្បីធ្វើការបង្ហាញជូនដល់សមាជិករដ្ឋសភា និងព្រឹទ្ធសភា អំពីការវិភាគរបស់ខ្លួនទៅលើច្បាប់នេះតាមទស្សនៈវិស័យនៃកាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា។*

**១/ <u>គោលការណ៍ទូទៅ</u>**

គោលបំណងចម្បងនៃច្បាប់នេះ គឺដើម្បីផ្តល់ជាមូលដ្ឋានច្បាប់ច្បាស់លាស់សម្រាប់ប្រព័ន្ធតុលាការមួយឯករាជ្យ និងមានប្រសិទ្ធភាព ដែលមានសមត្ថភាពផ្តល់យុត្តិធម៌ដល់ជនគ្រប់រូបនៅកម្ពុជា។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ អាចត្រូវបានអនុវត្តនៅចំពោះមុខសាលាក្តីដែលបង្កើតឡើងដោយច្បាប់តែប៉ុណ្ណោះ។

*ការិយាល័យឧត្តមស្នងការ សូមផ្តល់អនុសាសន៍ឲ្យកំណត់គោលការណ៍ទូទៅមួយចំនួនពីការចាត់តាំងអង្គការតុលាការនៅក្នុងមាត្រា១ ដូចជា៖*

- *គោលការណ៍ឯករាជ្យភាពនៃតុលាការ និងចៅក្រម*
- *គោលការណ៍នៃការបែងចែកអំណាច (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)*
- *គោលការណ៍នៃភាពមិនលំអៀងរបស់ចៅក្រម*

[1] A/HRC/15/46, para.49.

គោលការណ៍ជាមូលដ្ឋានទាំងនេះ ត្រូវបានតំកល់ទុកក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ១៩៦៦ (ICCPR) ដែលប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីក្នុងឆ្នាំ១៩៩២។ យោងតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ICCPR គឺជាផ្នែកមួយនៃច្បាប់កម្ពុជា។

បទបញ្ញត្តិនៃ ICCPR ដែលពាក់ព័ន្ធបំផុត គឺមាត្រា១៤ ដែលការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ បទបញ្ញត្តិនេះរួមមានសិទ្ធិទទួលបានសវនាការជាសាធារណៈដោយ "សាលាជំរះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលបង្កើតឡើងដោយច្បាប់" ។ គណៈកម្មាធិការសិទ្ធិមនុស្សដែលជាស្ថាប័នឃ្លាំមើលអន្តរជាតិបង្កើតឡើងដោយ ICCPR បានអនុម័តសេចក្តីពន្យល់ទូទៅលេខ៣២ អំពីមាត្រា១៤ ដែលចែងពីការណែនាំលំអិតដល់រដ្ឋភាគីពីរបៀបបកស្រាយមាត្រា១៤។[2] ក្នុងឯកសារនេះ គណៈកម្មាធិការសិទ្ធិមនុស្សបានរំលឹកថា តុលាការគួរតែឯករាជ្យពីស្ថាប័ននីតិប្រតិបត្តិ និងនីតិបញ្ញត្តិរបស់រដ្ឋាភិបាល។[3]

គោលការណ៍ដែលបានរៀបរាប់ខាងលើ ត្រូវបានបញ្ចូលទៅក្នុងគោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ និង និងគោលការណ៍ណែនាំស្តីពីតួនាទីរបស់អយ្យការ។[4] គោលការណ៍ទាំងនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្នុងជំពូកស្តីពីតុលាការ។

ច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ គួរតែបញ្ជាក់យ៉ាងច្បាស់លាស់ ស្របតាមគោលការណ៍មូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការថា៖

> ឯករាជ្យភាពរបស់តុលាការ ត្រូវតែធានាការពារដោយរដ្ឋធម្មនុញ្ញ។ នេះជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា គោរព និងប្រតិបត្តិតាមឯករាជ្យភាពរបស់ស្ថាប័នតុលាការ។
>
> តុលាការត្រូវមានយុត្តាធិការលើគ្រប់រឿងក្តី ដែលមានចរិកលក្ខណៈតុលាការ និងត្រូវមានសមត្ថកិច្ចផ្តាច់មុខ ដើម្បីសម្រេចថាតើបញ្ហាដែលបានដាក់មកឲ្យសំរេច ស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងដោយច្បាប់។

---

[2] See full text of General Comment No.32 on Article 14 at http://cambodia.ohchr.org/EN/PagesFiles/PublicationsIndex.htm.
[3] See General Comment No.32 on Article 14, para.18.
[4] Both documents are available at http://cambodia.ohchr.org/EN/PagesFiles/PublicationsIndex.htm

*លើសពីនេះទៀត ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ឲ្យមានការបញ្ជាក់ឡើងវិញច្បាស់លាស់អំពីគោលការណ៍ឯករាជភាពនៃការិយាល័យអយ្យការ ពីតុលាការ។ មាត្រា៨ អាច (ស្របតាមគោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា) បញ្ជាក់ថា៖*

*ការិយាល័យអយ្យការត្រូវចែកឲ្យដាច់ពីមុខងារតុលាការ។*

## ២/. ឯករាជ្យភាពតុលាការ

គោលការណ៍ឯករាជភាពតុលាការមានន័យថា តុលាការមិនត្រូវជាកម្មវត្ថុនៃការជ្រៀតជ្រែកណាមួយឡើយ។ នេះសបញ្ជាក់ឲ្យឃើញផងដែរថា តុលាការមិនត្រូវរាយការណ៍អំពីសេចក្តីសម្រេចរបស់ខ្លួនទៅអាជ្ញាធរណាមួយឡើយ។ គោលការណ៍ឯករាជភាពតុលាការ ទាក់ទងយ៉ាងជិតស្និតទៅនឹងគោលការណ៍នៃការបែងចែកអំណាច ដែលចែងថា អំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងតុលាការត្រូវចែកដាច់ពីគ្នា។

ដូច្នេះ តុលាការ និងក្រសួងយុត្តិធម៌ ត្រូវបែងចែកឲ្យដាច់ពីគ្នាតាមតែអាចធ្វើទៅបាន ហើយក្រសួងយុត្តិធម៌មិនត្រូវជ្រៀតជ្រែកកិច្ចការដែលតុលាការចាត់ចែងតាមវិធីណាក៏ដោយ។ ក្នុងន័យនេះ លោកតំណាងពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានផ្តល់អនុសាសន៍ថា តុលាការកំពូលត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការគ្រប់គ្រងតុលាការជាន់ទាបនានា គឺមិនមែនក្រសួងយុត្តិធម៌ទេ។[5]

តួយ៉ាងដូចជា ប្រសិនបើតុលាការចាំបាច់ស្នើសុំសេវាកម្មពីចៅក្រមណាម្នាក់ពីតុលាការមួយទៀត ដោយសារតែមិនមានចៅក្រមជំនាញគ្រប់គ្រាន់ ដើម្បីសវនាការសំណុំរឿងពិសេសណាមួយ សំណើនោះត្រូវស្នើទៅឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ឬសាលាឧទ្ធរណ៍/តុលាការកំពូល មិនមែនស្នើសុំទៅក្រសួងយុត្តិធម៌ទេ។

*ដូច្នេះ ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ថា សំណើណាមួយពីតុលាការទាក់ទងនឹងការបែងចែកឡើងវិញនូវចៅក្រម ត្រូវធ្វើដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬសាលាឧទ្ធរណ៍/តុលាការកំពូល មិនមែនក្រសួងយុត្តិធម៌ទេ។ អាស្រ័យហេតុនេះ ឃ្លា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌" នៅក្នុងមាត្រា១៦ និង១៧ គួរត្រូវបានដាក់ជំនួសទៅតាមនោះដែរ។*

[5] A/HRC/15/46, para.69

ដូចគ្នានេះដែរ នៅពេលណាត្រូវផ្ទេរសំណុំរឿង ពីតុលាការមួយទៅតុលាការមួយ មិនគួរត្រូវសម្រេចដោយអំណាចនីតិប្រតិបត្តិទេ។ ទោះជាក្រសួងយុត្តិធម៌អាចមានការទទួលខុសត្រូវជាទូទៅខ្លះនៅក្នុងវិស័យរដ្ឋបាលតុលាការក៏ដោយ ក្រសួងយុត្តិធម៌មិនគួរមានអំណាចណាមួយអំពីការចាត់ឲ្យចៅក្រមណាម្នាក់ ឬតុលាការណាមួយ ត្រូវពិនិត្យលើសំណុំរឿងណាមួយជាពិសេសនោះទេ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា គួរកែសម្រួលមាត្រា១៩ និងដាក់ជំនួសឃ្លា "ក្រសួងយុត្តិធម៌" ដោយ "តុលាការកំពូល"។*

ចំពោះអធិការកិច្ចតុលាការវិញ កិច្ចការនេះត្រូវអនុវត្តឡើងដោយអនុលោមតាមគោលការណ៍ឯករាជភាពតុលាការ។

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា បើមានការធ្វើអធិការកិច្ចតុលាការដោយក្រសួងយុត្តិធម៌ តាមមាត្រា១១ ត្រូវតែមានការបើកចំហជាសាធារណៈ ពីបញ្ហាដែលត្រូវធ្វើអធិការកិច្ច ហើយថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវគ្រប់គ្រងពីការប្រព្រឹត្តទៅនៃអធិការកិច្ចទាំងនេះ ដើម្បីធានាថា កិច្ចការអធិការកិច្ចទាំងនេះមិនបង្កើត ឬនាំឲ្យមានការជ្រៀតជ្រែកមិនសមរម្យណាមួយក្នុងប្រព័ន្ធតុលាការ។*

រដ្ឋាភិបាលមានការទទួលខុសត្រូវក្នុងការធានាថា ប្រព័ន្ធតុលាការមានធនធានគ្រប់គ្រាន់ដើម្បីផ្តល់យុត្តិធម៌។ ដោយសារតែបច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌ទទួលបន្ទុករៀបចំសេចក្តីស្នើថវិការួមសម្រាប់វិស័យយុត្តិធម៌ ដែលរាប់បញ្ចូលទាំងថវិកាសម្រាប់តុលាការផង នេះជាបញ្ហាសំខាន់បំផុតដើម្បីធានាថា ការផ្តល់មូលនិធិដល់តុលាការមិនស្ថិតក្រោមកម្មវត្ថុនៃការជ្រៀតជ្រែកផ្នែកនយោបាយឡើយ។ ក្នុងករណីនេះ ក្រុមប្រឹក្សាពិគ្រោះយោបល់ចៅក្រមអឺរ៉ុប បានបញ្ជាក់ជាតួយ៉ាងថាសេចក្តីសម្រេចស្តីពីការបែងចែកមូលនិធិដល់តុលាការ ត្រូវតែចាត់វិធានការគោរពឲ្យបានតឹងរឹងបំផុតដល់ឯករាជភាពតុលាការ។[6]

---

[6] See Opinion no 2 (2001) of the Consultative Council of European Judges (CCJE) for the attention of the Committee of Ministers of the Council of Europe on the funding and management of courts with reference to the efficiency of the judiciary and to article 6 of the European Convention on Human Rights, available at https://wcd.coe.int/ViewDoc.jsp?Ref=CCJE%282001%29OP2&Sector=secDGHL&Language=lanEnglish&Ver=original&BackColorInternet=FEF2E0&BackColorIntranet=FEF2E0&BackColorLogged=c3c3c3

*ការិយាល័យ OHCHR ត្រូវបានលើកទឹកចិត្តដោយមើលឃើញថា បន្ទាប់ពីមតិយោបល់កាលពីលើកមុនរបស់ខ្លួន មាត្រា៧៩ ត្រូវបានតាក់តែងឡើងដើម្បីឲ្យតុលាការមានកញ្ចប់ថវិកាផ្ទាល់របស់ខ្លួន។ ក្នុងន័យនេះ ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ថា ត្រូវផ្តល់ធនធាន និងមន្ត្រីគ្រប់គ្រាន់ដល់តុលាការនីមួយៗ ដើម្បីអាចឲ្យពួកគេអាចរៀបចំសំណើថវិការបស់ពួកគេបាន។*

**៣/. <u>តុលាការអនីតិជន</u>**

មាត្រា១៤ នៃសេចក្តីព្រាងនេះ មានបង្ហាញនូវសភាឯកទេសមួយចំនួន នៅតាមតុលាការនីមួយៗ ដូចជាសភារដ្ឋប្បវេណី សភាព្រហ្មទណ្ឌ សភាពាណិជ្ជកម្ម និងសភាការងារជាដើម (សូមមើលមាត្រា៣៧ និងមាត្រា៥៥)។ បញ្ជីសភាឯកទេសនេះ មិនឃើញមានសភាអនីតិជននោះទេ។

មាត្រា៤០(៣) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកម្ពុជាជារដ្ឋភាគី ចែងថា "រដ្ឋភាគីត្រូវស្វះស្វែងរកឲ្យមានការលើកស្ទួយដល់ការកសាងច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័ន ដែលត្រូវអនុវត្តជាក់លាក់ចំពោះកុមារដែលត្រូវទទួលរងការចោទប្រកាន់ថាជាជនជាប់ចោទ ឬត្រូវទទួលស្គាល់ថាបានរំលោភបំពានច្បាប់ព្រហ្មទណ្ឌ"។[7]

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានតាក់តែង និងពិភាក្សាគ្នាជាច្រើនឆ្នាំមកហើយ តែសេចក្តីព្រាងនេះ នៅមិនទាន់ត្រូវបានបង្ហើយឲ្យរួចរាល់នៅឡើយ។ មានអនុសាសន៍ជាច្រើនពីស្ថាប័នអន្តរជាតិឲ្យមានការបង្កើតប្រព័ន្ធយុត្តិធម៌អនីតិជនមួយនៅកម្ពុជា។[8] កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលយកអនុសាសន៍នានាដែលស្នើដោយក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងកំឡុងពេលពិនិត្យរបាយការណ៍ជាសកលតាមកាលកំណត់របស់ខ្លួនឆ្នាំ២០១៤(UPR)។[9]

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍ ឲ្យដាក់បញ្ចូលក្នុងមាត្រា១៤ មាត្រា៣៧ និងមាត្រា៥៧ នូវ "សភាអនីតិជន" ក្នុងចំណោមបញ្ជីសភាឯកទេសនានា។*

**៤/. គណនេយ្យភាពរបស់តុលាការ**

រដ្ឋបាលតុលាការស្ថិតក្នុងស្ថានភាពត្រូវការចាំបាច់ពង្រឹងជាបន្ទាន់ ដើម្បីធ្វើឲ្យកាន់តែប្រសើរដល់តុលាការ និងការគ្រប់គ្រងសំណុំរឿង។

---

[7] See also Committee on the Rights of the Child, General Comment No.10 (2007) – children's rights in juvenile justice, CRC/C/GC/10.
[8] See for instance A/HRC/15/46, para.86; CAT/C/KHM/CO/2, para.23; and CRC/C/KHM/CO/2-3, para.77.
[9] A/HRC/26/16, para.118.93.

*ការិយាល័យ* OHCHR *ត្រូវបានលើកទឹកចិត្ត ដោយមើលឃើញនៅក្នុងមាត្រា១០ ថា តុលាការនីមួយៗត្រូវមានលេខាធិការដ្ឋានមួយដែលនឹងជួយដល់ប្រធានតុលាការដើម្បីគ្រប់គ្រងតុលាការ។ នេះគឺជាប្រការសំខាន់ដែលលេខាធិការដ្ឋានបែបនេះ ត្រូវមានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់។*

តុលាការត្រូវទទួលខុសត្រូវចំពោះមុខសាធារណជន (ហើយមិនមែនចំពោះមុខក្រសួងយុត្តិធម៌ទេ)ចំពោះសេវាកម្មដែលខ្លួនផ្តល់ឲ្យ។ គណនេយ្យភាពទាមទារឲ្យមានតម្លាភាព។ ក្នុងករណីនេះ តុលាការគួរតម្រូវឲ្យប្រមូល និងបោះពុម្ពផ្សាយព័ត៌មានអំពីសេវាកម្មដែលខ្លួនផ្តល់ឲ្យ។ ព័ត៌មាននេះនឹងមានសារប្រយោជន៍ផងដែរ នៅពេលរៀបចំសេចក្តីស្នើថវិកាសម្រាប់តុលាការនីមួយៗ។

តំណាងពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានផ្តល់អនុសាសន៍កាលពីលើកមុនថា "តុលាការនីមួយៗ គួរមានអ្នកចុះបញ្ជីរៀងៗខ្លួន និងមានប្រព័ន្ធសមស្រប ក្នុងការរក្សាកំណត់ហេតុ/សំណុំរឿង។ ចៅក្រមផ្ទាល់មិនត្រូវរក្សាសំណុំរឿងទុកជាប់ខ្លួន ឬយកសំណុំរឿងនោះតាមខ្លួនទៅតាមតុលាការផ្សេងទៀតឡើយ នៅពេលខ្លួនត្រូវផ្ទេរទៅតុលាការមួយទៀត។[10]

*ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ថា ច្បាប់នេះ គួរដាក់បញ្ចូលបទបញ្ញត្តិស្នើសុំតុលាការឲ្យប្រមូល និងបោះពុម្ពផ្សាយព័ត៌មានអំពីចំនួនរឿងក្តីដែលមិនទាន់ចាត់ការ ចំនួនសមាមាត្រនៃរឿងក្តីដែលមានតំណាងផ្នែកច្បាប់ ចំនួនសមាមាត្រនៃរឿងក្តីដែលចុងចោទមានវត្តមាននៅពេលជំនុំជម្រះក្តី រយៈពេលជាមធ្យមនៃដំណើរការនីតិវិធីតុលាការ អត្រានៃការឃុំខ្លួនបណ្តោះអាសន្ន/ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចំនួននៃសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍។ល។*

*ការិយាល័យ* OHCHR *ក៏សូមផ្តល់អនុសាសន៍ផងដែរថា ច្បាប់នេះ គួរដាក់បញ្ចូលបទបញ្ញត្តិមួយតម្រូវឲ្យតុលាការ រួមទាំងការិយាល័យអយ្យការ ផ្លាស់ប្តូរព័ត៌មានគ្នាឲ្យបានជាប្រព័ន្ធ និងជាប់លាប់ អំពីស្ថានភាពរឿងក្តីដែលមានជនជាប់ចោទនៅពន្ធនាគារ។*

[10] A/HRC/15/46, para.92

*ការិយាល័យអយ្យការគួរមានរបាយការណ៍ពីចំនួនរឿងក្តីចោទប្រកាន់ ចំនួនរឿងក្តីលើកលែងចោទ អំពីកិច្ចប្រជុំមន្ត្រីនគរបាលយុត្តិធម៌ជាមួយពន្ធនាគារ និងអនុសាសន៍ដែលបានធ្វើក្រោយពីកិច្ចប្រជុំនេះម្តងៗ និងអំពីការទៅត្រួតពិនិត្យមើលពន្ធនាគារ និងការិយាល័យនគរបាលដែលខ្លួនបានធ្វើក្នុងកំឡុងពេលនៃការសរសេររបាយការណ៍ម្តងៗ។*

*ដើម្បីជួយដល់ការងារនេះ គួរតែមានរូបមន្តនៃការសរសេររបាយការណ៍បែបនេះមួយ។ ការិយាល័យ* OHCHR *ត្រៀមខ្លួនជាស្រេចដើម្បីជួយគាំទ្រដល់ការតាក់តែងរូបមន្តបែបនេះ។*

**៨/. <u>តុលាការចល័ត</u>**

ការិយាល័យ **OHCHR** តែងតែគាំទ្រជានិច្ចដល់សំណើរឲ្យមានការរៀបចំសវនាការនៅខាងក្រៅតុលាការ ដើម្បីជួយសម្រួលដល់វត្តមានរបស់ជនជាប់ចោទ នៅចំពោះមុខចៅក្រម និងព្រះរាជអាជ្ញា។[11] មាត្រា១៨ ចែងថា "នៅពេលណាចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចអនុញ្ញាតឲ្យសាលាដំបូងរៀបចំសវនាការរបស់ខ្លួន នៅខាងក្រៅតុលាការបាន តាមការស្នើសុំរបស់ប្រធានសាលាដំបូងនោះ។"

ក្នុងករណីនេះ មាត្រា៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា ប្រធានសវនាការ អាចបង្គាប់ឲ្យសួរចំលើយជនជាប់ចោទ នៅទីកន្លែងជននោះនៅ។ ការសួរចំលើយនេះ ត្រូវធ្វើដោយប្រធានសវនាការ នៅចំពោះមុខព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវីរបស់ជនជាប់ចោទ។ នេះបញ្ជាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌ បានអនុញ្ញាតឲ្យមានសវនាការខ្លះនៅខាងក្រៅតុលាការរួចស្រេចទៅហើយ ដោយមិនចាំបាច់មានការអនុញ្ញាតិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នោះឡើយ។

*ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ឲ្យមានការកែសម្រួលមាត្រា១៨ ដោយអានដូចខាងក្រោម៖*

> *នៅពេលណាចាំបាច់ ប្រធានសាលាដំបូង ត្រូវអនុញ្ញាតឲ្យតុលាការរៀបចំសវនាការរបស់ខ្លួន នៅខាងក្រៅសាលាដំបូងបាន។*

---

[11] This possibility was discussed at the Workshop organised by the Court of Appeal on promoting cooperation between courts, prosecutors and prisons and held in Phnom Penh on 6-7 September 2012.

*ការិយាល័យ OHCHR សូមផ្តល់អនុសាសន៍បន្ថែមទៀតថា លទ្ធភាពរៀបចំសវនាការរបស់សាលាដំបូងនៅខាងក្រៅសាលាដំបូង ដូចមានចែងក្នុងមាត្រា១៨ ក៏គួរតែអនុញ្ញាតិឲ្យមានផងដែរដល់សាលាឧទ្ធរណ៍។*

**៦/. ប្រព័ន្ធនៃការត្រួតពិនិត្យឡើងវិញនៃបណ្តឹងឧទ្ធរណ៍**

មាត្រា១៤ កថាខ័ណ្ឌ៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចែងថា "បុគ្គលគ្រប់រូបដែលផ្តន្ទាទោសអំពីបទឧក្រិដ្ឋ ត្រូវមានសិទ្ធិទទួលបានការពិនិត្យឡើងវិញនូវការផ្តន្ទាទោស និងការកាត់ទោសនោះ ដោយតុលាការជាន់ខ្ពស់មួយស្របតាមច្បាប់។" ក្នុងប្រព័ន្ធតុលាការកម្ពុជាបច្ចុប្បន្ននេះ មានសាលាឧទ្ធរណ៍តែមួយប៉ុណ្ណោះ ដែលទទួលបណ្តឹងឧទ្ធរណ៍ពីសាលាដំបូងទូទាំងប្រទេស។ ទោះបីជាមានការធ្វើឲ្យប្រសើរឡើងក្នុងការគ្រប់គ្រងសំណុំរឿងនៅសាលាឧទ្ធរណ៍ក៏ដោយ ក៏បញ្ហានេះនៅតែត្រូវចំណាយពេលមួយគួរឲ្យកត់សំគាល់ មុនពេលសំណុំរឿងប្តឹងឧទ្ធរណ៍ត្រូវបានបើកសវនាការ។ កង្វះមធ្យោបាយដឹកជញ្ជូននៅអគ្គនាយកដ្ឋានពន្ធនាគារ រួមផ្សំនឹងបញ្ហាលំបាកក្នុងការចែករំលែកព័ត៌មានភ្លាមៗអំពីសវនាការឧទ្ធរណ៍ មានន័យថា ចុងចោទជាច្រើនមិនមានលទ្ធភាពចូលរួមសវនាការឧទ្ធរណ៍របស់គេនៅភ្នំពេញទេ បណ្តាលឲ្យមានការរំលោភបំពានដដែលៗពីសិទ្ធិរបស់គេ ក្នុងការការពារខ្លួនដោយផ្ទាល់នៅសវនាការ។

ការបង្កើតសាលាឧទ្ធរណ៍តាមតំបន់ អាចជួយដោះស្រាយបញ្ហានេះ ហើយនាំយកសេវាកម្មយុត្តិធម៌ឲ្យកាន់តែខិតជិតប្រជាជន ជាពិសេសចំពោះប្រជាជនទាំងឡាយដែលរស់នៅខេត្តឆ្ងាយៗ។ ក្នុងករណីនេះ ការិយាល័យ OHCHR សូមស្វាគមន៍ចំពោះការសំរេចបង្កើតសាលាឧទ្ធរណ៍នៅតាមតំបន់បែបនេះ។ ក្នុងរយៈពេលកំពុងរង់ចាំការបង្កើតសាលាឧទ្ធរណ៍តាមតំបន់ ក្រសួងយុត្តិធម៌អាចពិចារណាពីការបង្កើតសាលាឧទ្ធរណ៍ចល័ត តួយ៉ាង ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍ ដែលអាចទៅបើកសវនាការរឿងក្តីនៅតាមខេត្តជាដើម ដោយប្រើប្រាស់អគារសាលាដំបូងសំរាប់រយៈពេលមួយកំណត់។[12]

*ស្របតាមអនុសាសន៍កាលពីលើកមុន OHCHR ត្រូវបានលើកទឹកចិត្ត ដោយឃើញថាមាត្រា៣៩ ចែងពីការបង្កើតសាលាឧទ្ធរណ៍តាមតំបន់។ បញ្ហាដែលសំខាន់នោះគឺថា តុលាការថ្មីនេះ ត្រូវមានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់។*

[12] This possibility was discussed at the Workshop organised by the Court of Appeal on promoting cooperation between courts, prosecutors and prisons and held in Phnom Penh on 6-7 September 2012.

### ៧/. ភាពមិនលំអៀងរបស់ចៅក្រម

សិទ្ធិទទួលបានសវនាការដោយយុត្តិធម៌តម្រូវថា ចៅក្រមត្រូវតែមិនលំអៀង។ ដូចបានរៀបរាប់ខាងលើ សេចក្តីព្រាងច្បាប់នេះ ត្រូវតែគូសបញ្ជាក់ឡើងវិញពីគោលការណ៍អនាគតិរបស់ចៅក្រម។ ដូចគណៈកម្មាធិការសិទ្ធិមនុស្សបានរំលឹក គោលការណ៍នេះ មានទិដ្ឋភាពពីរយ៉ាង៖

ទី១៖ ចៅក្រមមិនត្រូវអនុញ្ញាតិឲ្យសាលក្រមរបស់ខ្លួនទទួលឥទ្ធិពលដោយសារភាពលំអៀងឬការរើសអើងផ្ទាល់ខ្លួន ឬក៏បុរេវិនិច្ឆ័យដែលមានស្រាប់អំពីករណីដោយឡែកណាមួយដែលដាក់នៅចំពោះមុខខ្លួននោះឡើយ ឬសំដែងតាមវិធីណាដែលលើកស្ទួយមិនត្រឹមត្រូវដល់ផលប្រយោជន៍ភាគីណាមួយ ហើយធ្វើឲ្យខូចប្រយោជន៍ដល់ភាគីមួយទៀត។

ទី២៖ តុលាការត្រូវតែបង្ហាញឲ្យឃើញផងដែរ ដល់សាធារណៈជនពីភាពមិនលំអៀងនេះ។ តួយ៉ាង សវនាការមួយដែលទទួលរងយ៉ាងខ្លាំងក្លាដោយការចូលរួមពីចៅក្រមតាមលក្ខន្តិកៈរបស់ខ្លួន ដែលគួរត្រូវបានប្តឹងដឹតចិត្តនោះ ជាធម្មតាមិនអាចចាត់ទុកថាមិនលំអៀងនោះទេ។[13]

ចៅក្រមមិនត្រឹមតែមិនលំអៀងនោះទេ គាត់ត្រូវតែធ្វើឲ្យគេឃើញថាគាត់មិនលំអៀងផង។ គោលការណ៍អនាគតិនេះ បង្កើតកាតព្វកិច្ចមួយដល់ចៅក្រមឲ្យបោះបង់រឿងក្តីក្នុងករណីដែលខ្លួនយល់ថាមិនអាចសំរេចក្តីដោយមិនលំអៀងបាន ឬក្នុងករណីដែលអាចបង្ហាញដល់សាធារណៈជនថា ខ្លួនមិនអាចសំរេចក្តីលើបញ្ហានេះដោយមិនលំអៀងបាននោះទេ។[14] ក្នុងករណីបែបនេះ ចៅក្រមគួរដកខ្លួនពីការចូលរួមក្នុងនីតិវិធីតុលាការ ដោយមិនចាំបាច់មានសំណើពីគូភាគីនោះទេ។ វិធានអំពីការដកខ្លួនបែបនេះ គឺជាឧទាហរណ៍មួយមានចែងនៅក្នុងវិធាន៣៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។[15]

*ការិយាល័យ OHCHR ត្រូវបានលើកទឹកចិត្ត ដោយមើលឃើញថា សេចក្តីព្រាងច្បាប់នេះ មានបទប្បញ្ញត្តិតម្រូវឲ្យចៅក្រម បោះបង់រឿងក្តីចាប់ពីមាត្រា៧៤ដល់មាត្រាមាត្រា៧៧។*

---

[13] See General Comment No.32 on Article 14, para.21.

[14] See *The Bangalore Principles of Judicial Conduct*, adopted by the Judicial Group on Strengthening Judicial Integrity, as revised at the Round Table Meeting of Chief Justices at The Hague, 2002, Principle 2.5.

[15] Available at http://www.eccc.gov.kh/en/document/legal/internal-rules-rev8

*ការិយាល័យ* OHCHR *សូមផ្ដល់អនុសាសន៍ឲ្យបន្ថែមទៅលើមាត្រា៧៤ ដល់មាត្រា៧៧ នូវលក្ខខណ្ឌតម្រូវនានាដល់ចៅក្រម និងព្រះរាជអាជ្ញា បោះបង់រឿងក្ដីដែលខ្លួន ឬសមាជិកគ្រួសារមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍ហិរញ្ញវត្ថុ ឬការជាប់ពាក់ព័ន្ធដែលអាចប៉ះពាល់ដល់ភាពមិនលំអៀងរបស់ខ្លួន ឬបង្កើតជាការបង្ហាញពីភាពលំអៀងយ៉ាងជាក់ច្បាស់។*

**៨/. ++តុលាការយោធា++**

សព្វថ្ងៃនេះ មានតុលាការយោធាមួយនៅកម្ពុជា មានទីតាំងនៅរាជធានីភ្នំពេញ ហើយមានយុត្តាធិការទូទាំងប្រទេស។ ចំពោះករណីតុលាការយោធានេះ គណៈកម្មាធិការសិទ្ធិមនុស្ស បានទទួចថា បទបញ្ញត្តិនៃមាត្រា១៤(នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) អនុវត្តគ្រប់តុលាការ និងសាលាជំរះក្ដី ក្នុងវិសាលភាពនៃមាត្រានេះ ទោះជាធម្មតា ឬឯកទេស ស៊ីវិល ឬយោធា។[16]

ការិយាល័យ **OHCHR** សូមកត់សំគាល់ថា ជំពូកស្ដីពីតុលាការយោធា ត្រូវបានលប់ចោលពីសេចក្ដីព្រាងនេះ ហើយកត់សំគាល់ថា មាត្រា៨១ ចែងពីតម្រូវការមានច្បាប់ថ្មីអំពីបញ្ហានេះ។

*ការិយាល័យ* OHCHR *សូមផ្ដល់អនុសាសន៍ថា បទបញ្ញត្តិខ្លះនៃច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះតុលាការយោធាដែរ។ ជាពិសេស ច្បាប់នេះគួរបញ្ជាក់ឲ្យបានច្បាស់ពីគោលការណ៍ទូទៅសំរាប់ការចាត់តាំងតុលាការដែលត្រូវចែងតាំងពីជំពូងទីនៃច្បាប់នេះ (រួមទាំងឯករាជ្យភាពតុលាការនិងចៅក្រម ការបែងចែកអំណាច និងភាពមិនលំអៀងរបស់ចៅក្រម) ក៏ត្រូវយកមកអនុវត្តចំពោះតុលាការយោធា និងចៅក្រមយោធាដែរ។*

នៅទីណាមានតុលាការយោធា គោលបំណងនៃតុលាការនេះគឺគ្រាន់តែបំរើឲ្យតម្រូវការវិន័យជាក់លាក់នៃវិស័យយោធា។ តាមពាក្យពេជ្រដែលលោកតំណាងពិសេសស្ដីពីឯករាជភាពចៅក្រម និងមេធាវី យុត្តាធិការតាមហេតុផលនៃរឿងក្ដីដែលពាក់ព័ន្ធ *ratione materiae* នៃតុលាការយោធាគួរត្រូវបានកំរិតត្រឹមតែ "បទល្មើសព្រហ្មទណ្ឌ ដែលមានចរិកលក្ខណៈជាយោធាយ៉ាងតឹងរឹង ឬ

---
[16] See General Comment No.32 on Article 14, para.22.

និយាយម្យ៉ាងទៀតសំដៅដល់បទល្មើសដែលតាមចរិកលក្ខណៈផ្ទាល់នៃបទល្មើសនេះ ទាក់ទងទាំងស្រុងដល់ផលប្រយោជន៍នៃសណ្តាប់ធ្នាប់យោធាដែលត្រូវការពារតាមផ្លូវច្បាប់ ដូចជាការរត់ចោលជួរទៅខាងខ្មាំង ភាពរឹងរូស ឬការបោះបង់ចោលតួនាទី ឬបញ្ជា។[17] យោធិនជាប់ចោទពីបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌធម្មតា គួរតែជំនុំជម្រះដោយតុលាការធម្មតា។

ចំពោះករណីយុត្តាធិការតាមហេតុផលនៃរឿងក្តីដែលពាក់ព័ន្ធ ទោះបីជាច្បាប់អន្តរជាតិមិនបានហាមប្រាមយ៉ាងជាក់ច្បាស់ ឲ្យមានសវនាការជនស៊ីវិលដោយតុលាការយោធាក៏ដោយ ក៏តលូវនេះ មានការឯកភាពគ្នាជាឯកច្ឆ័ន្ទយ៉ាងច្បាស់លាស់ថា ការអនុវត្តបែបនេះ គួរតែជាករណីពិសេស[18] ឬក៏ត្រូវហាមប្រាមតែម្តង។[19]

*ការិយាល័យ* OHCHR *សូមផ្តល់អនុសាសន៍ថា ច្បាប់នេះត្រូវកំណត់ឲ្យបានច្បាស់ និងជាក់លាក់ពីវិសាលភាពនៃយុត្តាធិការតុលាការយោធា ដោយកំណត់ត្រឹមតែយោធិនដែលជាប់ចោទពីបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌដែលមានចរិកលក្ខណៈជាយោធាយ៉ាងតឹងរឹង។*

*រៀបរៀងដោយការិយាល័យ* OHCHR *នៅកម្ពុជា*

*ភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤*

[17] See A/68/285, para.98.
[18] See General Comment No.32 on Article 14, para.22.
[19] See A/68/285, para.101.